ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ១១៤៦ សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៦

# ប្រកាស

## ស្តីពីការបង្កើតគណៈកម្មការដឹកនាំគំរោងស្វ័យប្រវត្តិកម្មការងារគយ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រម នស/រកម/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស. ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស. រកម. ០១៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ. បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញសេចក្តីសំរេចលេខ០០៥ សហវ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការកែសំរួល និងបំពេញបន្ថែមលើគោលការណ៍គ្រប់គ្រងមន្ត្រីរាជការគយ និងរដ្ឋាករ

- បានឃើញប្រកាសលេខ៩២០ សហវ ប្រក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីចាត់ការគយ និងរដ្ឋាករ
- បានឃើញកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និង UNCTAD ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៦ ស្តីពីគំរោង ASYCUDA
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១ :** បង្កើតគណៈកម្មការដឹកនាំគំរោងស្វ័យប្រវត្តិកម្មការងារគយដែលភាសាអង់គ្លេសហៅថា Project Steering Committee ។

**ប្រការ ២ :** គណៈកម្មការដឹកនាំគំរោងមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត ប៉ែន ស៊ីម៉ន | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ | ប្រធាន |
| ២. លោក សៀង ឈុនទ្រី | នាយករងទី១ នៃទីចាត់ការគយ-រដ្ឋាករ | អនុប្រធាន |
| ៣. លោក គុណ ញឹម | នាយករង នៃទីចាត់ការគយ-រដ្ឋាករ | សមាជិក |
| ៤. តំណាងក្រសួងពាណិជ្ជកម្ម | | សមាជិក |
| ៥. តំណាង UNCTAD | | សមាជិក ។ |

**ប្រការ ៣ :** គណៈកម្មការដឹកនាំគំរោងមានភារៈកិច្ចដូចតទៅ÷

- **ដឹកនាំរួមទូទៅលើការអនុវត្តគំរោង ASYCUDA ។**
- **ផ្តល់ការណែនាំ ចង្អុលបង្ហាញទិសដៅអំពីការគ្រប់គ្រងគំរោងដល់ក្រុមការងារគំរោងជាតិ ។**
- **ពិនិត្យ និងឯកភាពលើកម្មវិធីអនុវត្តគំរោង ព្រមទាំងពិនិត្យនិងសំរេចទៅលើអនុសាសន៍លើតម្រូវការផ្លាស់ប្តូរជាគន្លឹះ ដែលបានលើកឡើងដោយក្រុមការងារគំរោងជាតិ ។**
- **ពិនិត្យ តាមដាន និងវាយតំលៃលើវឌ្ឍនភាពនៃការអនុវត្តគំរោង ព្រមទាំងសំរេចលើជំហាននៃដំណាក់កាលរបស់គំរោង ។**
- **ធ្វើរបាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តគំរោងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។**

**ប្រការ ៤ :** ក្នុងការអនុវត្តការងារពាក់ព័ន្ធនឹងប្រការ៣ខាងលើ និងការងារពាក់ព័ន្ធនឹងកិច្ចសំរួលពាណិជ្ជកម្ម ប្រធានគណៈកម្មការដឹកនាំគំរោងមានសិទ្ធិអញ្ជើញមន្ត្រីជំនាញនៃស្ថាប័នពាក់ព័ន្ធមកចូលរួមប្រជុំតាមការចាំបាច់ ។

**ប្រការ ៥:** ប្រកាស ឬសេចក្តីសំរេចណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៦ :** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និង រដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ និងសាម៉ីខ្លួនត្រូវទទួលអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ចំលងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ការិយាល័យធនាគារពិភពលោកប្រចាំនៅកម្ពុជា
  «ដើម្បីជូនជ្រាប»
- ដូចប្រការ៦ «ដើម្បីអនុវត្ត»
- កាលប្បវត្តិ-ឯកសារ